មជ្ឈមណ្ឌលឯកសារកម្ពុជា

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌: អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៧

## ប្រធានបទ: យុត្តិធម៌ និងការអត់ឃ្លានសម័យបច្ចុប្បន្ន


*ដោយ : វ៉េនឌល ឌីហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ : ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែកញ្ញា ឆ្នាំ២០១៣*


*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៧ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្រ្ត និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិ-ធម៌ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា* FM105.75 MHz *រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈវិទ្យុខេត្តកំពត* FM93.25 *វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈវិទ្យុខេត្តព្រះវិហារ* FM99 *វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង* FM103.25 *វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។*

ការផ្សាយនៅក្នុងវគ្គទី៧នេះ ផ្តោតសំខាន់ទៅលើ ថាតើការយល់ដឹងរបស់មនុស្សទាក់ទងនឹងការអត់ឃ្លានមានការប្រែប្រួលដែរឬទេ ហើយថាតើការអត់ឃ្លានជាលទ្ធផលនៃកត្តានយោបាយ មនុស្ស និង ការធ្លាក់ចុះនៃផលិតកម្មស្បៀងអាហារប្តយ៉ាងណា ។ នៅក្នុងវគ្គនេះ យើងខ្ញុំនឹងលើកយកការអត់ឃ្លានសម័យបច្ចុប្បន្នដែលបានកើតឡើងនៅប្រទេសកូរ៉េខាងជើង ប្រទេសអេចូពី (Ethiopia) តំបន់ដាហ្វ័រ (Darfur) និងច្បាប់ខុក្រិដ្ឋកម្មអន្តរជាតិ ។

## សេចក្តីផ្តើមៈ ការអត់ឃ្លានក្នុងសតវត្សរ៍ទី២០

អស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមក ការអត់ឃ្លានត្រូវបានទទួលស្គាល់ថា បានបង្កឡើងដោយគ្រោះធម្មជាតិ ឬកត្តាផ្សេងៗដែលប៉ះពាល់ទៅដល់បរិមាណស្បៀង ដែលផលិតនៅក្នុង ប្រទេស ឬតំបន់មួយដែលរងគ្រោះដោយសារគ្រោះទុរភិក្ស ។ និយមន័យនេះ សបញ្ជាក់ឲ្យឃើញថា ការអត់ឃ្លាន គឺជាហានីភ័យមួយដែលមិនអាចជៀសផុត ហើយមានការពាក់ព័ន្ធជាមួយនឹងមនុស្ស ។ ការយល់ឃើញបែបនេះ ត្រូវបានទទួលស្គាល់ថាជា "ទ្រឹស្តីម៉ាលសឹស" (Malthusian) បន្ទាប់ពីអ្នកប្រាជ្ញម្នាក់ឈ្មោះ រ៉ូបឺត ម៉ាលសឹស (Robert Malthus) បានសរសេរការវិភាគដ៏មានឥទ្ធិពល មួយចំនួនទាក់ទងទៅនឹងការអត់ឃ្លាននៅចុងសតវត្សរ៍ឆ្នាំ១៧០០ ។ នៅក្នុងទ្រឹស្តីនៃការអត់ឃ្លាន ដែលបង្កើតឡើងដោយ រ៉ូបឺត ម៉ាលសឹស ដោយសារតែការអត់ឃ្លានកើតឡើងនៅក្នុងប្រទេសមួយ ដែលមានប្រជាជនច្រើនលើសលុប ឬមានការផលិតស្បៀងមិនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ប្រជាជន ដូចច្នេះ ដើម្បីការពារកុំឲ្យកើតមានការអត់ឃ្លាន យើងត្រូវផ្តោតសំខាន់ទៅលើការបង្កើនផលិតកម្មស្បៀង និងដោះស្រាយរាល់បញ្ហាបច្ចេកទេសផ្សេងៗ ដូចជាការពង្រឹងមធ្យោបាយដឹកជញ្ជូន ឬកន្លែងស្តុកស្បៀងជាដើម ។ ទស្សនៈនេះត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាទាក់ទងទៅនឹងគ្រោះអត់ឃ្លានរហូតដល់ចុងសតវត្សរ៍ទី២០ ។ បន្ទាប់មក មានអ្នកប្រាជ្ញថ្មីៗមួយចំនួន ដូចជា អាម៉ាតយ៉ា សែន (Amartya Sen) បានចាប់ផ្តើមធ្វើការចោទសួរ ថាតើទ្រឹស្តីនេះពិតជាត្រឹមត្រូវគ្រប់កាលៈទេសៈ ដែរឬទេ ។

មូលហេតុនៃការយល់ឃើញទាក់ទងនឹងគ្រោះអត់ឃ្លានរបស់ ម៉ាលសឹស ត្រូវបានចោទជាសំណួរ ដោយសារតែទស្សនៈនៃការអត់ឃ្លាននោះ មិនបានឆ្លុះបញ្ចាំងត្រឹមត្រូវពីការអត់ឃ្លាន ដែលកើតមាននៅក្នុងសតវត្សរ៍ទី២០នោះទេ ។ បើតាមទ្រឹស្តី ម៉ាលសឹស (Malthusian) ដើម្បីទប់ស្កាត់គ្រោះអត់ឃ្លាន ត្រូវធ្វើយ៉ាងណាដោះស្រាយបញ្ហាបច្ចេកទេស ដូចជា ការផលិត និងការដឹកជញ្ជូន

អាហារ ដើម្បីផ្គត់ផ្គង់ប្រជាជននៅក្នុងប្រទេសនីមួយៗ ។ ប៉ុន្តែ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ភាពជឿនលឿនខាងបច្ចេកវិទ្យាបានដោះស្រាយបញ្ហាប្រឈមចម្បងៗមួយចំនួន ដែលជាដំណោះស្រាយក្នុងការលុបបំបាត់គ្រោះអត់ឃ្លាននៅទូទាំងសាកលលោក ឧទាហរណ៍ដូចជា ជី គ្រឿងម៉ាស៊ីន ទូរទឹកកក និងការដឹកជញ្ជូនផ្សេងៗ បានផ្តល់លក្ខណៈងាយស្រួលដល់ការបង្កបង្កើនផលក្នុងទ្រង់ទ្រាយធំ និងបានសម្រួលដល់ដំណើរការដឹកជញ្ជូនផលិតផលម្ហូបអាហារទៅកាន់តំបន់ផ្សេងៗ ដោយមិនបានធ្វើឲ្យផលិតផលទាំងនោះខូចគុណភាពទៀតផង ។ ថ្វីបើ មានភាពជឿនលឿនផ្នែកបច្ចេកវិទ្យាយ៉ាងណាក៏ដោយ ការអត់ឃ្លាននៅតែកើតមានឡើងនៅក្នុងសតវត្សរ៍ទី២០ដដែល ។ មិនតែប៉ុណ្ណោះ នៅតាមតំបន់ជាច្រើន ការអត់ឃ្លានបែរជាមានសភាពធ្ងន់ធ្ងរជាងការអត់ឃ្លាន ដែលធ្លាប់កើតមានពីមុនៗទៅទៀត ។ ជាក់ស្តែង នៅក្នុងសតវត្សរ៍ទី២០ មានជនរងគ្រោះប្រមាណជាង៧០លាននាក់បានស្លាប់ ដោយសារការអត់ឃ្លាន ។

នៅពាក់កណ្តាលសតវត្សទី២០ អ្នកប្រាជ្ញមួយចំនួនបានចាប់ផ្តើមធ្វើការស៊ើបអង្កេតទៅលើឫសគល់នៃការអត់ឃ្លាន និងធ្វើការឆ្លើយតបទៅនឹងផ្នែកមួយចំនួននៃ ទ្រឹស្តីម៉ាលសឹស (Malthusian) ។ នៅពេលដែលក្រុមអ្នកប្រាជ្ញទាំងនោះ ធ្វើការពិនិត្យពិច័យទៅលើការអត់ឃ្លានដែលបានកើតឡើង ក្រុមអ្នកប្រាជ្ញទាំងនោះបានធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នាថា បម្រែបម្រួលនៃផលិតកម្មស្បៀងអាហារនៅក្នុងប្រទេស ឬតំបន់ផ្សេងៗដែលទទួលរងគ្រោះដោយសារគ្រោះអត់ឃ្លាន មិនមានជាប់ទាក់ទងទៅនឹងទីកន្លែងដែលមានគ្រោះអត់ឃ្លាននោះទេ ។ ផ្ទុយទៅវិញ ក្រុមអ្នកប្រាជ្ញទាំងនោះបានយល់ឃើញថា កត្តាមួយចំនួន ដូចជា កត្តានយោបាយ កត្តាសង្គម និងកត្តាច្បាប់ មានសារៈសំខាន់ក្នុងការទប់ស្កាត់គ្រោះអត់ឃ្លាន ។ ជាឧទាហរណ៍ នៅក្នុងទសវត្សរ៍ឆ្នាំ៨០ គ្រោះអត់ឃ្លានដ៏ធ្ងន់ធ្ងរមួយបានកើតឡើងនៅក្នុងប្រទេសអេចូពី (Ethiopia) ដែលនៅភាគខាងជើងនៃទ្វីបអាហ្រ្វិក ។ គ្រោះអត់ឃ្លាននេះបង្កឡើងដោយសារអាកាសធាតុមិនល្អ ដែលធ្វើឲ្យទិន្នផលស្បៀងមានការថយចុះ ។ ប៉ុន្តែ យើងសង្កេតឃើញថា គ្រោះអត់ឃ្លានធ្ងន់ធ្ងរបានកើតឡើងនៅក្នុងតែប្រទេសអេចូពី (Ethiopia) តែប៉ុណ្ណោះ ។ ចំណែកឯប្រទេសជិតខាងផ្សេងទៀត ដែលទទួលរងលក្ខខណ្ឌអាកាសធាតុមិនល្អដូចគ្នានោះ កើតមានគ្រោះអត់ឃ្លានដែរ ប៉ុន្តែ មិនមានលក្ខណៈធ្ងន់ធ្ងរ ដូចប្រទេសអេចូពី (Ethiopia) នោះទេ ។ ជាងនេះទៅទៀត គ្រោះអត់ឃ្លានដែលបានកើតឡើងនៅក្នុងប្រទេសអេចូពី (Ethiopia) នៅពេលនោះ ត្រូវបានរកឃើញថាកើតមានឡើងនៅក្នុងតំបន់មួយជាក់លាក់ ដែលតំបន់នោះជាកន្លែងរបស់ក្រុមដែលប្រឆាំងនឹងរដ្ឋាភិបាល ។ រឿងរ៉ាវស្រដៀងគ្នានេះ ក៏បានកើតឡើងផងដែរ នៅក្នុងរបបខ្មែរក្រហម ។ នៅពេលដែលប្រទេសថៃ ឡាវ និងវៀតណាម មិនបានជួបប្រទះគ្រោះអត់ឃ្លាន ដោយសារអាកាសធាតុក្តៅហួត

ហែងនៅឆ្នាំ១៩៧៧ ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមនៅក្នុងឆ្នាំនោះគឺមានសភាពធ្ងន់ធ្ងរ ។ ជាលទ្ធផលនៃការរកឃើញទាំងនេះ ក្រុមអ្នកប្រាជ្ញដែលធ្វើការសិក្សាពីការអត់ឃ្លាន បានសង្កេតឃើញថា កត្តានយោបាយ សង្គម និងច្បាប់ផ្សេងៗមានសារៈសំខាន់ក្នុងការការពារ និងបញ្ឈប់គ្រោះអត់ឃ្លាន ដែលការរកឃើញនេះ ខុសគ្នាពីអ្វីដែល ទ្រឹស្តីម៉ាលសឹស (Malthusian) បានលើកឡើង ។

## ការអត់ឃ្លាន និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិៈ ដំណើរដែលនៅមានកម្រិតនៅឡើយ

ការផ្លាស់ប្តូរការយល់ដឹងទៅលើការអត់ឃ្លាននាសម័យបច្ចុប្បន្ននេះ កើតមានឡើងស្របពេលជាមួយនឹង ការបង្កើតច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិថ្មីៗ ដែលបានបង្កើតឲ្យមានតុលាការយោធាអន្តរជាតិនៅទីក្រុងនួរីមបឺក (Nuremberg) និងតុលាការពិសេសៗមួយចំនួនផ្សេងទៀត ដូចជា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នៅប្រទេសហុល្លង់ ជាដើម ។

អ្នកប្រាជ្ញមួយចំនួនដែលមានវិជ្ជាជីវៈផ្សេងៗគ្នា បានលើកឡើងថា ការប្រើប្រាស់ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ គួរតែបង្កើតជាផ្នែកមួយក្នុងការបញ្ឈប់ការអត់ឃ្លាន ។ អ្នកប្រាជ្ញមួយចំនួនក៏បានអះអាងថា ការអត់ឃ្លានដែលបានកើតឡើងមួយចំនួន មានការពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាការអត់ឃ្លាននៅក្នុងប្រទេសអ៊ុយក្រែន (Ukraine) ដែលជាផ្នែកមួយនៃអតីតសហភាពសូវៀត បានកើតឡើងចន្លោះឆ្នាំ១៩៣២-១៩៣៣ នៅក្នុងប្រទេសអេចូពី (Ethiopia) ចន្លោះឆ្នាំ១៩៨២-១៩៨៥ នៅក្នុងប្រទេសកូរ៉េខាងជើង ចាប់ពីទសវត្សរ៍ឆ្នាំ៩០រហូតដល់បច្ចុប្បន្ន តំបន់ដាហ៊្វ័រ (Dafur) នៃប្រទេសស៊ូដង់ (Sudan) ចាប់ពីឆ្នាំ១៩៨៥រហូតដល់បច្ចុប្បន្ន និងប្រទេសសូម៉ាលី (Somalia) ចាប់ពីឆ្នាំ២០១១រហូតដល់បច្ចុប្បន្ន ។ អ្នកប្រាជ្ញមួយចំនួនទៀតក៏បានលើកឡើងដែរថា ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមក៏មានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិដែរ ។

បើទោះបីជាមានការទាមទារឲ្យមានការជំនុំជម្រះជាអន្តរជាតិ ទៅលើបុគ្គលទាំងឡាយ ដែលបានបង្កឲ្យមានការអត់ឃ្លានយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ការអនុវត្តជាក់ស្តែងក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ពាក់ព័ន្ធនឹងការអត់ឃ្លាននៅមានលក្ខណៈតិចតួចនៅឡើយ ។ ក្រៅពីការជំនុំជម្រះទោសមន្ត្រីមួយចំនួនរបស់បក្សណាស៊ីអាឡឺម៉ង់ (Nazi) ដែលជឿថាបានបង្កឲ្យការអត់ឃ្លានទៅលើជនជាតិជ្វីត (Jews) នៅអឺរ៉ុប និងផ្នែកខ្លះនៃប្រទេសប៉ូឡូញ (Poland) ក្នុងអំឡុងនៃសង្គ្រាមលោកលើកទី២ ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតទាក់ទងនឹងការអត់ឃ្លានហាក់ដូចជាពុំត្រូវបាន

យកចិត្តទុកដាក់សោះ ។ ផ្ទុយទៅវិញ ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិភាគច្រើន ផ្តោតតែទៅលើអំពើហិង្សាដោយផ្ទាល់ រួមមាន ការសម្លាប់រង្គាល និងការធ្វើទារុណកម្ម ជាដើម ។

## ការអត់ឃ្លាននៅតំបន់ដាហ្វ័រ (Darfur) និងសំណុំរឿងដែលទាក់ទងនឹងលោកបាហ្សៀ (Bashir) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)

នៅតំបន់ដាហ្វ័រ (Darfur) នៃប្រទេសស៊ូដង់ (Sudan) តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានចេញដីកាចោទប្រកាន់លោកប្រធានាធិបតី អូម៉ា អាល់បាហ្សៀ (Omar Al-Bashir) និងបក្ខពួកមួយចំនួនទៀត ពីបទឧក្រិដ្ឋកម្មមួយចំនួន ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែការបង្កលក្ខខណ្ឌរស់នៅដ៏អាក្រក់ទៅលើប្រជាជនស៊ីវិលនៅក្នុងតំបន់ដាហ្វ័រ (Dafur) ។ ការអត់ឃ្លាន គឺជាសមាសធាតុចម្បងមួយនៃលក្ខខណ្ឌរស់នៅ ដែលបង្កឲ្យមានការរីករាលដាលនៃជម្ងឺ និងការកើនឡើងនៃចំនួនអ្នកស្លាប់នៅតំបន់ដាហ្វ័រ ហើយនេះក៏ទំនងជាករណីដែលអាចនាំយក លោក អាល់បាហ្សៀ និងបក្ខពួកទៅជំនុំជម្រះផងដែរ ។ នៅក្នុងករណីនេះ ការជំនុំជម្រះបានចោទប្រកាន់ថា អំពើប្រល័យពូជសាសន៍បានកើតមានឡើងប្រឆាំងនឹងជនជាតិភាគតិច ហ្វ័រ (Fur) ម៉ាសាលីត (Masalit) និងហ្សាហ្គាវ៉ា (Zaghawa) នៅតំបន់ដាហ្វ័រ(Dafur) ដោយការបង្កឲ្យមានលក្ខខណ្ឌរស់នៅមិនសមរម្យដែលប៉ះពាល់ដល់រូបរាងទៅលើក្រុមជនជាតិភាគតិច ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រយោធារបស់រដ្ឋាភិបាលស៊ូដង់ ។ នៅក្នុងដីកាចាប់ខ្លួនលោក អាល់បាហ្សៀ (Al-Bashir) លើកទីពីរ បានចោទលោកពីបទផ្គត់ផ្គង់ទឹកដែលមានដាក់ថ្នាំបំពុល ការបណ្តេញចេញពីទីក្រុងដោយហិង្សា និងការជម្រុញឲ្យសមាជិកនៃក្រុមជនជាតិភាគតិចតាំងទីលំនៅ នៅលើទឹកដីដែលមានការជម្លៀសដោយបង្ខំ ។ នៅក្នុងសំណុំរឿងដែលបានបញ្ជូនទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានលើកឡើងពាក់ព័ន្ធនឹងស្ថានភាពនៅតំបន់ដាហ្វ័រ (Dafur) ដែលបានអះអាងថាសកម្មភាពទាំងឡាយដែលបង្កឲ្យមានការអត់ឃ្លានកើតឡើងនៅក្នុងតំបន់ដាហ្វ័រ (Dafur) គឺជាផ្នែកមួយនៃគម្រោងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលរៀបចំឡើងដោយលោកប្រធានាធិបតី បាហ្សឺ (Bashir) និងបក្ខពួករបស់គាត់ ។ នៅក្នុងការចោទប្រកាន់ដែលពាក់ព័ន្ធនឹងតំបន់ដាហ្វ័រ (Dafur) បានលើកឡើងថា “មានជនរងគ្រោះប្រមាណ ៨ម៉ឺន៣ពាន់នាក់ បានស្លាប់ដោយសារ ការរងរបួស ការបង្អត់អាហារ កង្វះទឹក ឬលក្ខខណ្ឌរស់នៅអាក្រក់ផ្សេងៗ នៅក្នុងជំរុំជនភៀសខ្លួន” ចន្លោះពីខែកញ្ញា ឆ្នាំ២០០៣ ដល់ខែមករា ឆ្នាំ២០០៥ ។

## *ការអត់ឃ្លាននៅប្រទេសកូរ៉េខាងជើង នឹងការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ*

*លោក ម៉ាហ្សូគី ដារូសម៉ែន* (Marzuki Darusman) *អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកូរ៉េខាងជើង បានផ្ញើរបាយការណ៍មួយនៅដើមឆ្នាំ២០១៣នេះ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ដោយស្នើសុំឲ្យមានការស៊ើបអង្កេតមួយទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសកូរ៉េខាងជើង។ នៅក្នុងរបាយការណ៍នោះ លោក ម៉ាហ្សូគី ដារូសម៉ែន* (Marzuki Darusman) *បានលើកឡើងបញ្ហាចំនួន៩ ដែលជាប់ពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្សនៅប្រទេសកូរ៉េខាងជើង ចាប់តាំងពីឆ្នាំ២០០៤ ដែលអាចឈានទៅដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការរំលោភលើសិទ្ធិទទួលបានចំណីអាហារ "ដែលផ្ដោតទៅលើគោលនយោបាយរដ្ឋពាក់ព័ន្ធនឹងការចែកចាយចំណីអាហារទៅឲ្យប្រជាជន និងការរិតត្បិតការផ្ដល់ជំនួយមនុស្សធម៌អន្តរជាតិនៅពេលដែលមានវិបត្តិកង្វះស្បៀងអាហារ។" នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានធ្វើការបោះឆ្នោត ដើម្បីបង្កើតគណៈកម្មាការស៊ើបអង្កេតមួយដែលមានរយៈពេលមួយឆ្នាំ ដោយធ្វើការស៊ើបអង្កេតទៅលើការរំលោភបំពាននានា ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់លោក ដារូសម៉ែន* (Darusman)*។ លទ្ធផលនៃរបាយការណ៍នេះ ទំនងជាមានឥទ្ធិពលខ្លាំងក្នុងការកំណត់ ថាតើគោលនយោបាយរបស់កូរ៉េខាងជើងដែលបង្កឲ្យមានការអត់ឃ្លានកើតឡើង អាចត្រូវបានយកមកជំនុំជម្រះទោសដែរឬទេ។*

## *សេចក្ដីសន្និដ្ឋាន*

*ការអត់ឃ្លានធ្ងន់ធ្ងរ ដែលបង្កឲ្យមានជនរងគ្រោះជាច្រើននាក់ស្លាប់ដោយសារការអត់អាហារ និងជម្ងឺដែលពាក់ព័ន្ធនឹងការអត់ឃ្លាន បានកាត់បន្ថយនៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ បច្ចុប្បន្នការអត់ឃ្លានធ្ងន់ធ្ងរ បានកើតឡើងនៅពេលមានសង្គ្រាម ពេលមានចលាចល និងរដ្ឋាភិបាលផ្ដាច់ការតែប៉ុណ្ណោះ។ ស្ថានភាពទាំងនេះ ឆ្លុះបញ្ចាំងឲ្យឃើញថា គ្រោះអត់ឃ្លានសម័យបច្ចុប្បន្ន មានការពាក់ព័ន្ធទៅនឹងកត្តាមនុស្ស មិនមែនកត្តាធម្មជាតិ ដែលបង្កឲ្យមានការថយចុះនូវផលិតកម្មស្បៀងអាហារនោះទេ។ ដូចដែលបានពិភាក្សានៅក្នុងវគ្គមុនរួចមកហើយថា ការអត់ឃ្លានដែលបង្កឡើងដោយមេដឹកនាំខ្មែរក្រហម អាចចាត់ទុកជាបទឧក្រិដ្ឋបាន ដែលប្រឆាំងនឹងប្រជាជនកម្ពុជា បើទោះបីជាបទឧក្រិដ្ឋនេះមិនត្រូវបានលើកយកមកជំនុំជម្រះនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ។ ការអត់ឃ្លានដែលបានកើតឡើងថ្មីៗ ដូចជា នៅក្នុងប្រទេសសូម៉ាលី តំបន់ដាហ្វួរ និងប្រទេសកូរ៉េខាងជើង*

អាចនឹងត្រូវបានយកមកជំនុំជម្រះទោសនៅថ្ងៃណាមួយមិនខាន ។ យើងសង្ឃឹមថាកិច្ចខិតខំប្រឹងប្រែងផ្នែកច្បាប់ នឹងអាចជួយជម្រុញឲ្យមានការបញ្ឈប់ការបង្អត់អាហារប្រជាជន នៅទូទាំងពិភពលោក នៅពេល អនាគតដ៏ខ្លីខាងមុខ ។

(ជាបន្តទៅនេះ យើងខ្ញុំសូមលើកសំណួររបស់ប្រិយមិត្តអ្នកស្តាប់ដែលបានផ្ញើមកកាន់វិទ្យុសហគមន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។)

**សំណួររបស់ប្រិយមិត្តអ្នកស្តាប់**

**ឆ្លើយដោយ លោក *វ៉ាន់ឌី ខឹមហ្គាល់គូ***

១. ហេតុអ្វីបានជាខ្មែរក្រហមបង្អត់បាយប្រជាជនខ្លួនឯង នៅពេលដែលផលដំណាំមានច្រើន? តើផលដំណាំទាំងនោះត្រូវបានខ្មែរក្រហមដឹកជញ្ជូនទៅណា?

- ចម្លើយៈ ទីមួយ ខ្មែរក្រហមមានគម្រោងផលិតស្រូវឲ្យបានច្រើន ពោលគឺ ៣តោនក្នុង ១ហិចតា ។ ប៉ុន្តែ ទិន្នផលនេះមិនធ្លាប់ទទួលបានជោគជ័យនោះទេ នៅពេលដែលខ្មែរក្រហមកាន់អំណាច ។ ទីពីរ ផែនការសេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្មជឿនលឿន តាមរយៈការលក់ស្រូវទៅកាន់ទីផ្សារអន្តរជាតិ ដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់អនុវត្តផែន ការរបស់ខ្លួន ។ កត្តាទាំងអស់នេះ បានបង្កជាសម្ពាធយ៉ាងខ្លាំងដល់កម្មាភិបាលថ្នាក់ក្រោមតាមតំបន់ ដោយធ្វើយ៉ាងណាផ្តល់នូវទិន្នផលស្រូវឲ្យបានគ្រប់តាមផែនការកំណត់ របស់ថ្នាក់ដឹកនាំមជ្ឈិម ដើម្បីផ្គត់ផ្គង់ដល់យោធាខ្មែរក្រហម និងលក់ទៅប្រទេសដទៃ សម្រាប់ដោះដូរជាប្រាក់កាស និងទំនិញដែលខ្មែរក្រហមមិនអាចផលិតបាន ។

២. ហេតុអ្វីបានជាខ្មែរក្រហមឲ្យប្រជាជនធ្វើការធ្ងន់?

- ចម្លើយៈ ខ្មែរក្រហមបានថ្លែងថា គោលនយោបាយរបស់ខ្លួនគឺ រស់នៅឯករាជ្យម្ចាស់ការ នេះមានន័យថា មិនមានជំនួយបរទេសនោះទេ ។ ខ្មែរក្រហមក៏ មានគម្រោងធ្វើឲ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខ "មហាលោតផ្លោះ" ដើម្បីក្លាយជាប្រទេសសង្គមនិយមមួយដ៏រីកចម្រើន និង ធ្វើឲ្យប្រទេសកម្ពុជាមានការរីកលូតលាស់ជាងប្រទេសសង្គមនិយមដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាម ជាដើម ។ ដោយសារតែ ខ្មែរក្រហមពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មប្រជាជន ដើម្បីសម្រេចឲ្យផែនការរបស់ខ្លួន ជាលទ្ធផល ប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងច្រើនម៉ោង ។

៣. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង?

- ចម្លើយៈ វាមានកត្តាជាច្រើនដែលបានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងទ្រង់ទ្រាយធំ ។ កត្តាទាំងនោះ រួមមាន ការកាប់សម្លាប់ លក្ខខណ្ឌរស់នៅ និងការបង្អត់អាហារ ។ ខ្មែរក្រហមមានបំណងប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយមមួយដ៏បរិសុទ្ធ ។ ខ្មែរក្រហមយល់ឃើញថា ខ្លួនមានសត្រូវជាច្រើន ទាំងជនជាតិខ្មែរ និងជនជាតិបរទេស ដែលធ្វើការរារាំងផែនការបដិវត្តន៍របស់ខ្លួន ។ ជាលទ្ធផល ខ្មែរក្រហមមានការភ័យខ្លាច និងព្រួយបារម្ភកាន់តែខ្លាំងឡើងៗចំពោះបញ្ហានេះ ។ មេដឹកនាំខ្មែរក្រហមក៏បានស្តីបន្ទោសទៅលើខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលបានធ្វើឲ្យផែនការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតារបស់ខ្លួនបរាជ័យ ។ ដូច្នេះនៅតំបន់ណាដែលមិនអាចបំពេញតាមផែនការរបស់ខ្មែរក្រហមបាន ខ្មែរក្រហមចាប់ផ្តើមធ្វើការបោសសំអាតតំបន់នោះដោយអំពើហិង្សា ។ ដោយសារតែ មានការប្រើអំពើហិង្សា និងលក្ខខណ្ឌរស់នៅមិនសមរម្យ កត្តាទាំងអស់នេះបានបង្កឲ្យការសម្លាប់ប្រជាជនក្នុងលក្ខណៈទ្រង់ទ្រាយធំ ។

៤. ហេតុអ្វីបានជាខ្មែរក្រហមបំបែកគ្រួសារមិនឲ្យរស់នៅជុំគ្នា?

- មេដឹកនាំខ្មែរក្រហមដឹងថា គ្រួសារមានសារៈសំខាន់ និងទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសង្គមខ្មែរ ។ មេដឹកនាំខ្មែរក្រហមគិតថា ប្រជាជនកម្ពុជាគ្រប់រូបគួរតែស្មោះត្រង់នឹងបដិវត្តន៍របស់ខ្លួនជាងសមាជិកគ្រួសារ ។ មេដឹកនាំខ្មែរក្រហម ក៏ប្រមើលមើលឃើញថា គ្រួសារ គឺជាបញ្ហាប្រឈមមួយ ចំពោះផែនការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជារដ្ឋសង្គមនិយមមួយដ៏ស្អាតស្អំ ។ ដូច្នេះ ដើម្បីសម្រេចផែនការនេះ ខ្មែរក្រហមមិនបានគិតពីទំនាក់ទំនងគ្រួសារនៅក្នុងសង្គមកម្ពុជានោះទេ ។ ហេតុផលមួយផ្សេងទៀតចំពោះការបំបែកបំបាក់គ្រួសារ ដោយសារតែខ្មែរក្រហមត្រូវការកម្លាំងពលកម្មដើម្បីបំពេញការងារទៅតាមគោលដៅបដិវត្តន៍ ដូច្នេះ ប្រជាជនត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់តំបន់ផ្សេងៗពីគ្នា ។

៥. ហេតុអ្វីបានជាមិនមានប្រជាជនណាម្នាក់ធ្វើការប៉ះបោរនឹងខ្មែរក្រហម?

- បានជាប្រជាជនមិនធ្វើការប៉ះបោរនឹងខ្មែរក្រហម ដោយសារតែៈ ទីមួយ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទៅកាន់តំបន់ផ្សេងៗគ្នា ដែលធ្វើឲ្យប្រជាជនមានការពិបាកក្នុងការបង្កើតក្រុម ដើម្បីធ្វើការប្រឆាំងតបតនឹងយោធាខ្មែរក្រហម ។ ទីពីរ នៅតាមទីជនបទ ប្រជាជនខ្មែរត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា ។ ប្រសិនបើប្រជាជនណាម្នាក់ត្រូវបានចោទប្រកាន់ថាបាន និយាយអ្វីមិនល្អប៉ះពាល់ដល់បដិវត្តន៍ ប្រជាជន

រូបនោះនឹងត្រូវខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងអាចត្រូវបានខ្មែរក្រហមសម្លាប់ ។ កត្តានេះបានបង្កឲ្យមានភាពលំបាកកាន់តែខ្លាំងឡើងសម្រាប់ប្រជាជនកម្ពុជា ដើម្បីរៀបចំក្រុមប៉ះបោរប្រឆាំងនឹងខ្មែរក្រហម ។ ទីបី ដោយសារតែ ប្រជាជនកម្ពុជា ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ស្ទើរតែស្លាប់ និងការបង្អត់អាហារ ។ ដូច្នេះ ប្រជាជនកម្ពុជាពុំមាន កម្លាំងគ្រប់គ្រាន់ក្នុងការប្រឆាំងតបតនឹងខ្មែរក្រហមនោះទេ ។ ទីបួន កម្មាភិបាលខ្មែរក្រហមគ្រប់ភូមិស្រុកមានអាវុធកាន់គ្រប់ដៃ ចំណែកឯប្រជាជនកម្ពុជាពុំមានអាវុធអ្វីអាចធ្វើវាយបកនឹងខ្មែរក្រហមបាននោះទេ ។ នៅក្នុងរបបខ្មែរក្រហម ក៏ធ្លាប់មានព្រឹត្តិការណ៍ប៉ះបោរកើតឡើងដែរ ។ ព្រឹត្តិការណ៍កើតឡើងនៅក្នុងភូមិមួយ នៅពេលដែលមេដឹកនាំខ្មែរអ៊ីស្លាម នៅក្នុងភូមិមួយត្រូវបានខ្មែរក្រហមសម្លាប់ និងការប្រតិបត្តិសាសនា និងប្រពៃណីត្រូវបានលុបបំបាត់ ។ ប៉ុន្តែការប៉ះបោររបស់ប្រជាជនខ្មែរអ៊ីស្លាមនៅក្នុងភូមិនោះ ត្រូវបានខ្មែរក្រហមបង្ក្រាបទៅវិញ នៅពេលដែលប្រជាជនខ្មែរអ៊ីស្លាមទាំងនោះពុំមានអាវុធអ្វី ក្រៅពីកាំបិត និងដាវ ។ បន្ទាប់មកប្រជាជនខ្មែរអ៊ីស្លាមដែលបានចូលរួមប៉ះបោរ ត្រូវបានខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ។

៦. តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬទេ?

- បច្ចុប្បន្ន តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានចេញសាលក្រមទាក់ទងនឹងជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាមេគុកទួលស្លែង ។ ស្របពេលនឹងគ្នានេះដែរ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំពុងបន្តដំណើរការកាត់ក្តីទៅលើជនជាប់ចោទពីររូបផ្សេងទៀត ដែលជាអតីតមេដឹកនាំខ្មែរក្រហម រួមមាន នួន ជា និង ខៀវ សំផន ។ បុគ្គលម្នាក់ៗមានការយល់ឃើញខុសគ្នាទៅលើអត្ថន័យនៃពាក្យ "យុត្តិធម៌" ហើយ ថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬយ៉ាងណានោះជាការយល់ឃើញរបស់ជនរងគ្រោះម្នាក់ៗ ។

*សំណួរផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយៈ*

- *អ៊ុំប សុខសិរីមន្នីកា, ខេត្តព្រះវិហារ*
- *ភក្រ្តា, ខេត្តព្រះវិហារ*
- *សុភា, ខេត្តព្រះវិហារ*

នេះជាចុងបញ្ចប់នៃវគ្គទី៧ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌកឯកសារកម្ពុជា ដែលនិយាយពីការអត់ឃ្លាន នៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងការផ្សាយនៃវគ្គបន្ទាប់ យើងខ្ញុំនឹងពិភាក្សាអំពីសំណុំរឿងចាស់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងគ្រោះទុរភិក្ស និងការបង្អត់អាហារ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស្ទីឌីយោថតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗ នៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និង ម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។